Washington State Department of Health

Updated September 12, 2022

DOH 820-131 Khmer

# ការណែនាំអំពីម៉ាស់អំឡុងពេលមានជំងឺ COVID–19

## ខ្លឹមសារសង្ខេបអំពីការកែប្រែនានានៅថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 2022

- ការបន្ថែមព័ត៌មានស្តីពីកម្រិតផ្សេងគ្នានៃការការពារដែលផ្តល់ដោយម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើម
- ការធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របតាមការណែនាំអំពីការពាក់ម៉ាស់របស់ Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ) សម្រាប់មធ្យោបាយធ្វើដំណើរសាធារណៈក្នុងអគារ
- ការធ្វើបច្ចុប្បន្នភាពការណែនាំអំពីថាតើនៅពេលណាគួរតែពាក់ម៉ាស់នៅក្នុងមជ្ឈដ្ឋានប្រមូលផ្តុំដែលមិនមែនជាកន្លែងថែទាំសុខភាព
- ការធ្វើបច្ចុប្បន្នភាពការណែនាំអំពីថាសាធារណជនទូទៅគួរតែពាក់ម៉ាស់នៅក្នុងអគារនៅពេលណាស្របតាមកម្រិតឆ្លងជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC

## សេចក្តីផ្តើម

នៅពេលអ្នកពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើម (ឧ. ម៉ាស់តម្រងឯកទេសដូចជា N95) អ្នកជួយការពារអ្នកដទៃនៅជុំវិញអ្នក ក៏ដូចជាខ្លួនអ្នកផងដែរ។ ការពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមអាចកាត់បន្ថយការចម្លងជំងឺ COVID-19 សង្គ្រោះអាយុជីវិត និងជួយឱ្យសេដ្ឋកិច្ចបន្តដំណើរការ។ យុទ្ធសាស្ត្ររួមដូចជាការចាក់វ៉ាក់សាំងទាន់សភាពការណ៍ (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) និងការពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមអាចជួយបង្ការជំងឺធ្ងន់ធ្ងរ ព្រមទាំងកាត់បន្ថយបន្ទុកមកលើប្រព័ន្ធថែទាំសុខភាព។

អ្នកគួរតែពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមដែលតឹងណែនល្អបំផុត និងមានគុណភាពខ្ពស់បំផុត (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ផ្តល់ជូនអ្នក។ នៅពេលពាក់បានត្រឹមត្រូវ ប្រដាប់ជំនួយការដកដង្ហើមដែលអនុម័តដោយ National Institute for Occupational Safety and Health (NIOSH, វិទ្យាស្ថានជាតិទទួលបន្ទុកផ្នែកសុវត្ថិភាពការងារ និងសុខភាព) (ភាសាអង់គ្លេសប៉ុណ្ណោះ) (ដូចជា N95) ផ្តល់ជូនការការពារបានល្អបំផុត បន្ទាប់មកប្រដាប់ជំនួយការដកដង្ហើមអន្តរជាតិ (ដូចជា KN95 និង KF94) និងម៉ាស់វះកាត់ បន្ទាប់មកទៀតម៉ាស់ក្រណាត់។ ប្រសិនបើអ្នកមានហានិភ័យអាចកើតជំងឺ COVID-19 ធ្ងន់ធ្ងរ សូមពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពអំពីថាតើអ្នកគួរតែធ្វើតេស្តមើលថាសមស្របក្នុងការពាក់ប្រដាប់ជំនួយការដកដង្ហើមដែលអនុញ្ញាតដោយ NIOSH ឬអត់ ឬថាតើអ្នកគួរតែពិចារណាលើជម្រើសប្រដាប់ជំនួយការដកដង្ហើមផ្សេងដែលមិនត្រូវឱ្យធ្វើតេស្តមើលថាតើសមស្របឬអត់។ ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីការធ្វើតេស្តមើលថាតើសមស្របឬអត់ និងការជ្រើសរើសម៉ាស់ សូមចូលទៅកាន់គេហទំព័រស្តីពីការពាក់ម៉ាស់ដោយស្ម័គ្រចិត្តរបស់ Washington State Department of Labor and Industries (L&I, ក្រសួងពលកម្ម និងឧស្សាហកម្មនៃរដ្ឋវ៉ាស៊ីនតោន) (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)។

ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីប្រភេទម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើមផ្សេងគ្នា និងរបៀបធ្វើឱ្យការពាក់កាន់តែត្រូវល្អម សូមមើលប្រភេទម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើម (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)។ គេហទំព័រនេះ (ភាសាអង់គ្លេសប៉ុណ្ណោះ) ផ្តល់ព័ត៌មានមួយចំនួនអំពីថាតើប្រភេទម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើមផ្សេងគ្នាត្រងភាគល្អិតតូចៗចេញបានល្អកម្រិតណា រួមទាំងនៅពេលមានការកែប្រែចំពោះម៉ាស់ដើម្បីឱ្យការពាក់កាន់តែតឹងណែនល្អ។ មនុស្សដែលមិនអាចពាក់ម៉ាស់ដោយសារតែបញ្ហាផ្នែកវេជ្ជសាស្ត្រ ការលូតលាស់ឬ អាកប្បកិរិយា អាចពាក់ក្បាំងមុខដែលមាននរាំងពីក្រោមបាន។ ក្បាំងមុខដែលមាននរាំងពីក្រោមទាំងនេះក៏អាចប្រើបានដោយកុមារក្នុងមណ្ឌលថែទាំកុមារ ជំរំថែទាំកុមារនាពេលថ្ងៃ និងមជ្ឈដ្ឋានថ្នាក់មត្តេយ្យដល់ថ្នាក់ទី12 ផងដែរ ប្រសិនបើមិនអាចទ្រាំនឹងម៉ាស់ដែលតឹងណែនល្អបានទេ។

ទោះជាយ៉ាងណាក៏ដោយ គួរតែទទួលស្គាល់ថាក្បាំងមុខដែលមានរនាំងពីក្រោមទាំងនេះមិនផ្តល់កម្រិតនៃការការពារសម្រាប់អ្នកពាក់ដូចគ្នានឹងម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមដែលតឹងណែនល្អទេ។ សូមមើលការណែនាំអំពីការពាក់ម៉ាស់របស់ Washington State Department of Health (WA DOH, ក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីនតោន) នៅ K-12 Schools (សាលារៀនថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12), Child Care (មណ្ឌលថែទាំកុមារ), Early Learning (ថ្នាក់មុនមត្តេយ្យ), Youth Development (ថ្នាក់អភិវឌ្ឍយុវជន) និងកម្មវិធី Day Camp (ជំរំថែទាំកុមារនាពេលថ្ងៃ) (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)។ សូមមើលការពិចារណាសម្រាប់ក្រុមមនុស្សជាក់លាក់របស់ CDC ផងដែរ (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)។ DOH មិនណែនាំឱ្យប្រើម៉ាស់ដែលមានសន្ទះ ឬរន្ធខ្យល់ដង្ហើមចេញ ឬម៉ាស់ក្រណាត់ដែលមានតែមួយស្រទាប់ កូនកន្សែង និងស្រោមការពារដែលមានតែមួយស្រទាប់នោះទេ។

ប្រដាប់ជំនួយការដកដង្ហើមដែលមានសន្ទះខ្យល់ដង្ហើមចេញអាចប្រើប្រាស់នៅក្នុងកន្លែងការងារស្របតាមការណែនាំដែលចេញផ្សាយដោយ L&I (ជាភាសាអង់គ្លេសតែប៉ុណ្ណោះ)។

សូមចូលមើលគេហទំព័ររបស់ DOH អំពីម៉ាស់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ដើម្បីមើលបញ្ជីសំណួរដែលចោទសួរជាញឹកញាប់អំពីម៉ាស់។

ចំណែកដែលនៅសល់ទាំងអស់នៃឯកសារនេះ ម៉ាស់ត្រូវបានប្រើសំដៅដល់ទាំងម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើម។

## សេចក្តីបង្គាប់ និងបទបញ្ជាសុខភាពបច្ចុប្បន្ន

សេចក្តីបង្គាប់សាធារណៈបច្ចុប្បន្នតម្រូវឱ្យប្រើម៉ាស់នៅក្នុងមជ្ឈដ្ឋានថែទាំសុខភាព ពន្ធនាគារសម្រាប់មនុស្សពេញវ័យ។ អាជ្ញាធរសុខភាពសាធារណៈអាចតម្រូវឱ្យប្រើម៉ាស់ក្នុងកាលៈទេសៈមួយចំនួន ដូចជាពេលផ្ទុះជំងឺជាដើម។

### សេចក្តីបង្គាប់របស់ Department of Health នៃរដ្ឋវ៉ាស៊ីនតោន

Secretary of Health Mask Order (សេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) តម្រូវឱ្យពាក់ម៉ាស់ក្នុងមជ្ឈដ្ឋានមួយចំនួន ដោយមិនគិតពីស្ថានភាពចាក់វ៉ាក់សាំងឡើយ៖

- មជ្ឈដ្ឋានថែទាំសុខភាព
- ពន្ធនាគារសម្រាប់មនុស្សពេញវ័យ និងពន្ធនាគារ ប្រសិនបើខោនធីដែលពន្ធនាគារនោះស្ថិតនៅ មានកម្រិតឆ្លងជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC មធ្យម ឬខ្ពស់ (ជាភាសាអេស្ប៉ាញតែប៉ុណ្ណោះ)

មានករណីលើកលែងមានកម្រិតចំពោះលក្ខខណ្ឌតម្រូវនេះ ករណីលើកលែងមានកម្រិតទាំងនេះអាចរកបាននៅក្នុងសេចក្តីបង្គាប់ (ភាសាអង់គ្លេសប៉ុណ្ណោះ)។ បុគ្គលិក និងភ្ញៀវទាំងអស់ ក្រៅពីអ្នកជំនាញថែទាំសុខភាព ត្រូវបានតម្រូវឱ្យពាក់ម៉ាស់ពេលស្ថិតនៅក្នុងមជ្ឈដ្ឋានថែទាំសុខភាព។ មនុស្សម្នាក់ៗមានទំនួលខុសត្រូវក្នុងការអនុវត្តតាម អាជីវកម្មក៏មានការទទួលខុសត្រូវក្នុងការអនុវត្តសេចក្តីបង្គាប់នេះទៅលើបុគ្គលិក និងអតិថិជនដែរ។

### ការលុបចោល៖ បទបញ្ជាសហព័ន្ធ

គិតត្រឹមថ្ងៃទី 18 ខែមេសា ឆ្នាំ 2022 តាមដីការបស់តុលាការ សេចក្តីបង្គាប់របស់ CDC ដែលតម្រូវឱ្យប្រើម៉ាស់នៅលើមធ្យោបាយធ្វើដំណើរសាធារណៈ និងនៅមជ្ឈមណ្ឌលដឹកជញ្ជូនលែងមានប្រសិទ្ធភាពអនុវត្តទៀតហើយ។ ទោះជាយ៉ាងណាក៏ដោយ ម៉ាស់នៅតែជាឧបករណ៍ដ៏សំខាន់មួយក្នុងការធ្វើឱ្យមធ្យោបាយធ្វើដំណើរសាធារណៈមានសុវត្ថិភាពជាងមុនសម្រាប់មនុស្សគ្រប់រូប។ ស្របតាម CDC (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) WA DOH ណែនាំឱ្យកម្មករ និងអ្នកដំណើរដែលមានអាយុចាប់ពីពីរឆ្នាំឡើងពាក់ម៉ាស់នៅក្នុងមជ្ឈដ្ឋានមធ្យោបាយធ្វើដំណើរសាធារណៈក្នុងអគារទាំងអស់ រួមទាំងមជ្ឈមណ្ឌលដឹកជញ្ជូន និងធ្វើដំណើរ។ សូមមើលមជ្ឈដ្ឋានមធ្យោបាយធ្វើដំណើរសាធារណៈដើម្បីទទួលបានព័ត៌មានបន្ថែម។

### សេចក្តីប្រកាសរបស់អភិបាលរដ្ឋវ៉ាស៊ីនតោន

ព័ត៌មានអំពីទំនួលខុសត្រូវរបស់អាជីវកម្មចំពោះអតិថិជន និងបុគ្គលិកត្រូវបានចុះក្នុង Proclamation 20-25.19 COVID-19 Washington Ready (សេចក្តីប្រកាសលេខ 20-25.19 ស្តីពីរដ្ឋវ៉ាស៊ីនតោនត្រៀមខ្លួនសម្រាប់ជំងឺ COVID-19) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និង Proclamation 21-08 – Safe Workers (សេចក្តីប្រកាសលេខ 21-08 – បុគ្គលិកមានសុវត្ថិភាព) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) របស់អភិបាលរដ្ឋ។

### Washington State Labor and Industries (L&I) និងសេចក្តីប្រកាសរបស់អភិបាលរដ្ឋ

ទោះបីជាមិនតម្រូវឱ្យពាក់ម៉ាស់ជាទូទៅក្នុងកន្លែងការងារភាគច្រើនតាមសេចក្តីប្រកាសរបស់អភិបាលរដ្ឋខាងលើក៏ដោយ ក៏បុគ្គលិកនៅតែមានកាតព្វកិច្ចគោរពតាមលក្ខខណ្ឌតម្រូវ និងការណែនាំដើម្បីបង្ការជំងឺ COVID-19 របស់ L&I (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ បន្ថែមពីនេះ អាជីវកម្មឯកជនអាចតម្រូវឱ្យប្រើម៉ាស់ ហើយភ្ញៀវគួរតែគោរពតាមវិធានតាមទីតាំង។ តាមរយៈ Proclamation 21-08 – Safe Workers (សេចក្តីប្រកាសលេខ 21-08 – បុគ្គលិកមានសុវត្ថិភាព) របស់អភិបាលរដ្ឋ (ជាភាសាអង់គ្លេសប៉ុណ្ណោះ) កម្មករមានសិទ្ធិពាក់ម៉ាស់នៅក្នុងកន្លែងការងារ។ Washington Administrative Code (WAC, ក្រមរដ្ឋបាលនៃរដ្ឋវ៉ាស៊ីនតោន) 296-62-609 (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ការពារសិទ្ធិរបស់កម្មករក្នុងការពាក់ម៉ាស់អំឡុងពេលមានអាសន្នផ្នែកសុខភាពសាធារណៈ។ ស្របតាម WAC 296-62-609 (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និយោជកមិនអាចរារាំងបុគ្គលិកមិនឱ្យពាក់ម៉ាស់ ប្រដាប់ជំនួយការដកដង្ហើម ឬឈុតការពារខ្លួន និងសម្ភារផ្សេងទៀតបានទេ លើកលែងតែមានការអនុញ្ញាតបន្ធូរបន្ថយដោយច្បាប់។ សូមមើលការបង្ការជំងឺ COVID-19 របស់ L&I៖ ការជ្រើសរើសពាក់ម៉ាស់ពេលធ្វើការនៅពេលដែលអ្នកមិនត្រូវបានតម្រូវឱ្យពាក់ (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ដើម្បីទទួលបានព័ត៌មានបន្ថែម។

### អង្គភាព និងមន្ត្រីសុខាភិបាលសាធារណៈក្នុងមូលដ្ឋាន

មន្ត្រីសុខាភិបាលក្នុងមូលដ្ឋានមានសិទ្ធិចេញបទបញ្ជាសុខភាពដើម្បីគ្រប់គ្រងជំងឺនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បទបញ្ជាទាំងនេះអាចមានភាពតឹងរ៉ឹងជាងបទបញ្ជាទូទាំងរដ្ឋ ប៉ុន្តែមិនអាចតឹងរ៉ឹងតិចជាងនេះទេ។ សូមសាកសួរមន្ត្រីមានសមត្ថកិច្ចផ្នែកសុខាភិបាលក្នុងមូលដ្ឋាន (ជាភាសាអង់គ្លេសប៉ុណ្ណោះ) របស់អ្នក និងអនុវត្តតាមបទបញ្ជាសុខភាពទាំងអស់ដែលមានសម្រាប់តំបន់នោះ។

## ការណែនាំ

ខាងក្រោមនេះគឺជាការណែនាំទូទៅអំពីសុខភាពសាធារណៈបន្ថែមលើលក្ខខណ្ឌតម្រូវជាក់លាក់ខាងលើ។

### មជ្ឈដ្ឋានមធ្យោបាយធ្វើដំណើរសាធារណៈ:

WA DOH ណែនាំឱ្យកម្មករ និងអ្នកដំណើរដែលមានអាយុចាប់ពីពីរឆ្នាំឡើងពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមដែលតឹងណែនល្អនៅក្នុងមជ្ឈដ្ឋានមធ្យោបាយធ្វើដំណើរសាធារណៈក្នុងអគារ (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) រួមទាំងការដឹកជញ្ជូន (ដូចជាយន្តហោះ រថយន្តក្រុង រថភ្លើង ស្រឡាង រថភ្លើងក្រោមដី តាក់ស៊ី ការធ្វើដំណើររួមគ្នា និងមធ្យោបាយដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រមិនបន្ទាន់) និងមជ្ឈមណ្ឌល (ដូចជាអាកាសយានដ្ឋាន រថយន្តក្រុង ឬកន្លែងរង់ចាំស្រឡាង រថភ្លើង ឬស្ថានីយរថភ្លើងក្រោមដី និងកំពង់ផែសមុទ្រ)។ មានមជ្ឈដ្ឋានដែលមនុស្សជាច្រើនឆ្លងកាត់ ហើយមជ្ឈដ្ឋានទាំងនោះអាចមានមនុស្សកកកុញ និង/ឬខ្យល់ចេញចូលមិនល្អ (ដូចជាផ្លូវដើរឡើងយន្តហោះរបស់អាកាសយានដ្ឋាន)។ អ្នកធ្វើដំណើរ និងកម្មករអាចការពារខ្លួនពួកគេ និងអ្នកដែលនៅជុំវិញពួកគេតាមរយៈការពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមដែលតឹងណែនល្អដើម្បីជួយធ្វើឱ្យការធ្វើដំណើរ និងមធ្យោបាយធ្វើដំណើរសាធារណៈកាន់តែមានសុវត្ថិភាពសម្រាប់អ្នកគ្រប់គ្នា។ សូមមើលការណែនាំស្តីពីការប្រើម៉ាស់នៅក្នុងមជ្ឈដ្ឋានមធ្យោបាយធ្វើដំណើរសាធារណៈរបស់ CDC (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ដើម្បីទទួលបានព័ត៌មានលម្អិត ប៉ុន្តែសូមចំណាំថាបច្ចុប្បន្ននេះលក្ខខណ្ឌតម្រូវគឺជាការណែនាំ។ សូមមើលលក្ខខណ្ឌតម្រូវ និងការណែនាំដើម្បីកាត់បន្ថយការចម្លងជំងឺ COVID-19 នៅ K-12 Schools

[(សាលារៀនថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12), Child Care (មណ្ឌលថែទាំកុមារ), Early Learning (ថ្នាក់មុនមត្តេយ្យ), Youth Development (ថ្នាក់អភិវឌ្ឍយុវជន) និងកម្មវិធី Day Camp (ជំរំថែទាំកុមារនាពេលថ្ងៃ) (wa.gov)] (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ដើម្បីទទួលបានការណែនាំស្តីពីការពាក់ម៉ាស់នៅលើរថយន្តដឹកសិស្ស។ WA DOH លើកទឹកចិត្តឱ្យអ្នកបញ្ជាមធ្យោបាយធ្វើដំណើរសាធារណៈគាំទ្រការពាក់ម៉ាស់របស់មនុស្សគ្រប់រូប។

## ការពាក់ម៉ាស់នៅក្នុងមជ្ឈដ្ឋានថែទាំសុខភាព

ម៉ាស់ត្រូវតែពាក់នៅក្នុងមជ្ឈដ្ឋានថែទាំសុខភាពស្របតាម[សេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល] (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ គ្រប់មជ្ឈដ្ឋានថែទាំសុខភាពទាំងអស់អាចចូលមើលការណែនាំស្តីពីឈុតការពារខ្លួន និងការគ្រប់គ្រងប្រភពនៅក្នុង[ការណែនាំបណ្តោះអាសន្នអំពីការបង្ការ និងការគ្រប់គ្រងការឆ្លងវីរុស SARS-CoV- 2 នៅក្នុងមជ្ឈដ្ឋានថែទាំសុខភាព DOH 420-391 (wa.gov)] (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។

## ការណែនាំអំពីការពាក់ម៉ាស់សម្រាប់មជ្ឈដ្ឋានប្រមូលផ្តុំដែលមិនមែនថែទាំសុខភាព

ការពាក់ម៉ាស់នៅក្នុងអគារត្រូវបានណែនាំសម្រាប់មនុស្សដែលមានអាយុចាប់ពីពីរឆ្នាំឡើងនៅពេលដែល[កម្រិតឆ្លងជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC] (ផ្តល់ជូនជាភាសាអេស្ប៉ាញ) មានកម្រិតមធ្យម ឬខ្ពស់នៅក្នុងមជ្ឈដ្ឋានដូចខាងក្រោម៖

- [គេហទំព័រអ្នកផ្តល់សេវាគ្មានផ្ទះសម្បែង] (ជាភាសាអង់គ្លេសប៉ុណ្ណោះ)
- [មជ្ឈដ្ឋានដែនសមុទ្រពាណិជ្ជកម្ម] (ជាភាសាអង់គ្លេសប៉ុណ្ណោះ) (ឧ. នាវាដឹកអាហារសមុទ្របែបពាណិជ្ជកម្ម នាវាដឹកទំនិញ នាវាទេសចរណ៍)
- មជ្ឈដ្ឋានការងារដែលមានមនុស្សកកកុញដែលការរក្សាគម្លាតរាងកាយមិនអាចធ្វើទៅបាន ដោយសារលក្ខណៈនៃកន្លែងការងារដូចជា ឃ្លាំង រោងចក្រ រោងចក្រកែច្នៃសាច់ និងការវេចខ្ចប់អាហារ និងមធ្យោបាយធ្វើដំណើរដែលផ្តល់ដោយនិយោជក
- កន្លែងរស់នៅរួមគ្នាក្នុងទីតាំងរស់នៅប្រមូលផ្តុំ (មិនមែនបន្ទប់គេង) រួមទាំងទីតាំងដោះលែងឱ្យធ្វើការ លំនៅដ្ឋានបណ្តោះអាសន្ន មន្ទីរឃុំឃាំងឬស្ថានីតិសម្បទាអនីតិជន និងលំនៅដ្ឋានកម្មករបណ្តោះអាសន្ន
- ក្នុងអគារនៃមជ្ឈដ្ឋានដែលមានមនុស្សជាប់ពន្ធនាគារសម្រាប់មនុស្សពេញវ័យ មណ្ឌលស្តារនីតិសម្បទាអនីតិជន ឬមន្ទីរឃុំឃាំងអនីតិជន (ឧ. បន្ទប់តុលាការ)
  - សូមចំណាំថាសេចក្តីបង្គាប់របស់លេខាធិការក្រសួងសុខាភិបាល<u>តម្រូវឱ្យ</u>មនុស្សដែលមានអាយុចាប់ពីប្រាំឆ្នាំឡើងពាក់ម៉ាស់នៅក្នុងពន្ធនាគារសម្រាប់មនុស្សពេញវ័យ និងពន្ធនាគារនៅពេលដែល[កម្រិតឆ្លងជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC] (មានផ្តល់ជូនជាភាសាអេស្ប៉ាញ) មានកម្រិតមធ្យម ឬខ្ពស់។
  - មណ្ឌលកែប្រែត្រូវបានណែនាំឱ្យពិចារណាលើការពាក់ម៉ាស់នៅពេលដែល[កត្តាកម្រិតមណ្ឌល] (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) បង្ហាញថាហានិភ័យមានការកើនឡើង។

បុគ្គលដែលរស់នៅ ឬធ្វើការក្នុងមជ្ឈដ្ឋានខាងលើគួរតែអនុវត្តតាមការណែនាំដូចគ្នាទៅនឹងសាធារណជនទូទៅដែរ នៅពេលមិនស្ថិតក្នុងមជ្ឈដ្ឋានទាំងនេះ (ឧ. នៅពេលចេញក្រៅក្នុងសហគមន៍)។

កន្លែងដែលមិនមែនថែទាំសុខភាព (ដូចជាអាជីវកម្ម និងអង្គការ) អាចតម្រូវឱ្យពាក់ម៉ាស់ក្នុងទីតាំងរបស់ខ្លួន។ កន្លែងទាំងនេះគួរតែពិចារណាលើកត្តានីមួយៗខាងក្រោម នៅពេលសម្រេចចិត្តថាតម្រូវឱ្យពាក់ម៉ាស់ក្នុងមជ្ឈដ្ឋានរបស់ខ្លួនឬអត់៖

- ភាពងាយរងគ្រោះរបស់មនុស្សក្នុងមជ្ឈដ្ឋាន
  - មនុស្សដែលមិនបានចាក់វ៉ាក់សាំងជំងឺ COVID-19 [ទាន់សភាពការណ៍] (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ទំនងជាងាយឆ្លងជំងឺ COVID-19 និងងាយវិវឌ្ឍទៅជាជំងឺធ្ងន់ធ្ងរ។

- មនុស្សដែលមានបញ្ហាសុខភាពជាក់លាក់ (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) មានហានិភ័យខ្ពស់ជាងនៃការកើតជំងឺ COVID-19 ធ្ងន់ធ្ងរ។
- គុណភាពប្រព័ន្ធខ្យល់ចេញចូលក្នុងមជ្ឈដ្ឋាន - សូមមើលប្រព័ន្ធខ្យល់ចេញចូល និងគុណភាពខ្យល់សម្រាប់កាត់បន្ថយការចម្លងជំងឺឆ្លងតាមខ្យល់ដង្ហើម (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងខ្យល់ស្អាត នៅក្នុងបញ្ហាប្រឈមរបស់អគារ, Environmental Protection Agency (EPA, ទីភ្នាក់ងារការពារបរិស្ថាន) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ដើម្បីជ្រាបព័ត៌មាន និងជម្រើសប្រព័ន្ធខ្យល់ចេញចូល រួមទាំងកន្លែងដែលមាននិងគ្មានប្រព័ន្ធកម្តៅ ខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់ (HVAC)
- លទ្ធភាពរក្សាគម្លាតរាងកាយរបស់មនុស្សក្នុងមជ្ឈដ្ឋាន
- ការផ្ទុះជំងឺ COVID-19 ដែលគេសង្ស័យ ឬមានការបញ្ជាក់នៅក្នុងមជ្ឈដ្ឋាន
    - ការប្រើម៉ាស់នៅក្នុងអគារត្រូវបានណែនាំយ៉ាងខ្លាំងនៅពេលមានការផ្ទុះជំងឺក្នុងមជ្ឈដ្ឋានប្រមូលផ្តុំដែលមិនមែនថែទាំសុខភាព។

នៅពេលកម្រិតឆ្លងជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ខ្ពស់ CDC និង DOH ណែនាំឱ្យមនុស្សគ្រប់រូបពាក់ម៉ាស់ក្នុងអគារ ដោយមិនគិតពីស្ថានភាពចាក់វ៉ាក់សាំងឡើយ។ កន្លែងនេះមិនគួរបង្អាក់ទឹកចិត្តបុគ្គលនានាមិនឱ្យពាក់ម៉ាស់ទេ ប្រសិនបើពួកគេសម្រេចចិត្តពាក់ម៉ាស់។ សូមមើលការណែនាំអំពីការពាក់ម៉ាស់ និងការពិចារណាផ្អែកលើហានិភ័យសម្រាប់បុគ្គលនៅខាងក្រោម។

## ការណែនាំអំពីម៉ាស់សម្រាប់បុគ្គល

មនុស្សដែលមានរោគសញ្ញា ធ្វើតេស្តឃើញវិជ្ជមាន ឬប៉ះពាល់នឹងនរណាម្នាក់ដែលមានផ្ទុកជំងឺ COVID-19 គួរតែពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមដែលមានគុណភាពខ្ពស់ស្របតាមអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមានជំងឺ COVID-19 (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) មេកផាងនៃការសម្រេចអំពីរោគសញ្ញាជំងឺ COVID-19 (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) និងអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកប្រហែលជាបានប៉ះពាល់នឹងនរណាម្នាក់ដែលមានផ្ទុកជំងឺ COVID-19 (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)។ បុគ្គលត្រូវតែពាក់ម៉ាស់ ប្រសិនបើមានការតម្រូវសម្រាប់មជ្ឈដ្ឋានដែលពួកគេស្ថិតនៅយោងទៅតាមសេចក្តីបង្គាប់ និងបទបញ្ជាសុខភាពបច្ចុប្បន្ន។

ក្នុងកាលៈទេសៈណាក៏ដោយ អ្នកអាចជ្រើសរើសពាក់ម៉ាស់បាន។ ពិចារណាលើកត្តាខាងក្រោម នៅពេលសម្រេចចិត្តថាត្រូវពាក់ម៉ាស់ឬអត់៖

- ស្ថានភាពចាក់វ៉ាក់សាំងរបស់អ្នក និងស្ថានភាពចាក់វ៉ាក់សាំងរបស់អ្នកដែលនៅជុំវិញអ្នក។ បុគ្គលដែលមិនបានចាក់វ៉ាក់សាំងជំងឺ COVID-19 និងជួសជុំរុញទាន់សភាពការណ៍(មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ងាយឆ្លងជំងឺ COVID-19 និងងាយវិវឌ្ឍជាជំងឺធ្ងន់ធ្ងរ។
- បញ្ហាសុខភាព (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) របស់អ្នក និងបញ្ហាសុខភាពរបស់អ្នកដែលនៅជុំវិញអ្នកមានហានិភ័យខ្ពស់ជាងនៃការកើតជំងឺ COVID-19 ធ្ងន់ធ្ងរ។ មនុស្សដែលមានបញ្ហាសុខភាពមួយចំនួនងាយឆ្លងជំងឺ COVID-19 និងងាយវិវឌ្ឍជាជំងឺធ្ងន់ធ្ងរ។
- មជ្ឈដ្ឋានដែលអ្នកស្ថិតនៅមានលក្ខណៈបែបណា (ឧ. មនុស្សកកកុញ ខ្យល់ចេញចូលមិនល្អ នៅក្នុងអគារ)។
- កម្រិតឆ្លងជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)
    - នៅពេលការឆ្លងជំងឺក្នុងសហគមន៍មានកម្រិតខ្ពស់ នោះ CDC និង WA DOH ណែនាំឱ្យមានការពាក់ម៉ាស់នៅក្នុងអគារ ដោយមិនគិតពីស្ថានភាពចាក់វ៉ាក់សាំងឡើយ។
    - នៅពេលការឆ្លងជំងឺក្នុងសហគមន៍មានកម្រិតមធ្យម ឬខ្ពស់ នោះ CDC និង WA DOH ណែនាំឱ្យមនុស្សដែលមានហានិភ័យខ្ពស់អាចឈឺធ្ងន់ (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) ពីជំងឺ COVID-19 ពាក់ម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមដែលមានគុណភាពខ្ពស់នៅពេលស្ថិតក្នុងអគារក្នុងទី

សាធារណៈ។ មនុស្សដែលប៉ះនៅក្នុងក្រុមគ្រួសារ ឬសង្គមខាងក្រៅជាមួយនរណាម្នាក់ដែលមានហានិភ័យខ្ពស់អាចឈឺធ្ងន់ គួរតែពិចារណាពាក់ម៉ាស់ដែលមានគុណភាពខ្ពស់នៅពេលស្ថិតក្នុងអគារជាមួយពួកគេ។

## ព័ត៌មាន និងធនធានច្រើនទៀតអំពីជំងឺ COVID-19

បន្តតាមដានព័ត៌មានថ្មីៗអំពីស្ថានភាពជំងឺ COVID-19 បច្ចុប្បន្ននៅរដ្ឋវ៉ាស៊ីនតោន (ជាភាសាអង់គ្លេសប៉ុណ្ណោះ) សេចក្ដីប្រកាសរបស់លោកអភិបាល Inslee (ជាភាសាអង់គ្លេសប៉ុណ្ណោះ) រោគសញ្ញា (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) របៀបដែលវារីករាលដាល (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន) របៀបនិងពេលដែលមនុស្សគួរតែធ្វើតេស្ត (ផ្តល់ជូនជាភាសាអេស្ប៉ាញ) និងកន្លែងដើម្បីស្វែងរកវ៉ាក់សាំង (ផ្តល់ជូនជាភាសាអេស្ប៉ាញ)។ សូមមើលសំណួរចោទសួរជាញឹកញាប់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ) របស់យើងសម្រាប់ព័ត៌មានបន្ថែម។

ពូជសាសន៍/ជនជាតិ ឬសញ្ជាតិរបស់មនុស្សម្នាក់ៗតែមួយមុខ មិនធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យខ្ពស់នៃ COVID-19 ឡើយ។ ទោះយ៉ាងណា ទិន្នន័យបង្ហាញថាសហគមន៍ជនជាតិស្បែកមិនសកំពុងរងផលប៉ះពាល់ខ្លាំងពី COVID-19។ នេះគឺដោយសារតែផលប៉ះពាល់នៃការរើសអើងជាតិសាសន៍ និងជាពិសេសការរើសអើងជាតិសាសន៍ជារចនាសម្ព័ន្ធ ដែលទុកឱ្យក្រុមជាតិសាសន៍ខ្លះមានឱកាសតិចតួចក្នុងការការពារខ្លួន និងសហគមន៍របស់ពួកគេ។ ពាក្យបង្អាប់បង្ខូចគ្នានឹងមិនជួយដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺនោះទេ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ ចែករំលែកព័ត៌មានត្រឹមត្រូវជាមួយអ្នកដទៃដើម្បីទប់ស្កាត់ពាក្យចចាមអារ៉ាម និងព័ត៌មានមិនពិតកុំឲ្យរីករាលដាលបាន។

- ការផ្ទុះវីរុសកូរ៉ូណាប្រភេទថ្មីឆ្នាំ 2019 (COVID-19) ពី Department of Health របស់រដ្ឋវ៉ាស៊ីនតោន (ជាភាសាអង់គ្លេសប៉ុណ្ណោះ)
- ការឆ្លើយតបចំពោះវីរុសកូរ៉ូណា (COVID-19) របស់រដ្ឋវ៉ាស៊ីនតោន (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)
- ស្វែងរកមណ្ឌល ឬក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នក (ជាភាសាអង់គ្លេសប៉ុណ្ណោះ)
- CDC វីរុសកូរ៉ូណា (COVID-19) (មានផ្តល់ជូនភាសាបន្ថែមមួយចំនួន)

**មានសំណួរបន្ថែមមែនទេ?** សូមហៅមកខ្សែទូរសព្ទបន្ទាន់ផ្នែកព័ត៌មានអំពីជំងឺ COVID-19 របស់យើងតាមរយៈលេខ 1-800-525-0127។ ម៉ោងខ្សែទូរសព្ទបន្ទាន់៖

- ថ្ងៃចន្ទពីម៉ោង 6 ព្រឹកដល់ម៉ោង 10 យប់
- ថ្ងៃអង្គារដល់ថ្ងៃអាទិត្យពីម៉ោង 6 ព្រឹកដល់ម៉ោង 6 ល្ងាច
- ថ្ងៃឈប់សម្រាករបស់រដ្ឋដែលបានកំណត់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ពីម៉ោង 6 ព្រឹកដល់ម៉ោង 6 ល្ងាច

សម្រាប់សេវាបកប្រែ **សូមចុច #** នៅពេលដែលមានអ្នកលើកទូរសព្ទ និងនិយាយភាសារបស់អ្នក។ សម្រាប់សំណួរអំពីសុខភាពផ្ទាល់ខ្លួន ឬលទ្ធផលធ្វើតេស្តរបស់អ្នក សូមទាក់ទងទៅអ្នកផ្តល់សេវាថែទាំសុខភាព។

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។
អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

## ឯកសារបន្ថែមខាងចុង A

**មជ្ឈដ្ឋានថែទាំសុខភាព**

យោងតាម Secretary of Health's Mask Order (សេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) មជ្ឈដ្ឋានថែទាំសុខភាព និងមជ្ឈដ្ឋានថែទាំរយៈពេលវែងគឺជាមជ្ឈដ្ឋានឯកជន ឬសាធារណៈទាំងឡាយដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាពដោយផ្ទាល់ដល់ប្រជាជន ដោយមានករណីលើក

លែងមួយចំនួន។ ប្រសិនបើស្ថិតក្នុងទីតាំងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាព ដូចជាមន្ទីរពេទ្យជាដើម នោះទីតាំងទាំងមូលគឺជាមជ្ឈដ្ឋានថែទាំសុខភាព ឬមជ្ឈដ្ឋានថែទាំរយៈពេលវែង ហើយត្រូវតែពាក់របាំងមុខទូទាំងទីតាំងនេះ ដោយអនុលោមតាមករណីលើកលែងក្នុងបទបញ្ជាស្តីពីរបាំងមុខ។ ប្រសិនបើស្ថិតក្នុងទីតាំងដែលប្រើជាចម្បងសម្រាប់គោលបំណងផ្សេងទៀត ដូចជាឱសថស្ថាននៅក្នុងហាងលក់គ្រឿងទេស ឬការិយាល័យគិលានុបដ្ឋាកប្រចាំសាលារៀន ជាដើម នោះមជ្ឈដ្ឋានថែទាំសុខភាព ឬមជ្ឈដ្ឋានថែទាំរយៈពេលវែងរាប់បញ្ចូលតែកន្លែងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាពប៉ុណ្ណោះ ប៉ុន្តែមិនរាប់បញ្ចូលកន្លែងផ្សេងទៀតនៃទីតាំងនេះទេ។ របាំងមុខត្រូវតែពាក់នៅកន្លែងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាព ដោយអនុលោមតាមករណីលើកលែងក្នុងបទបញ្ជាស្តីពីរបាំងមុខ។
លុះត្រាតែមិនរាប់បញ្ចូលខាងក្រោម
អ្នកផ្តល់សេវាថែទាំសុខភាពរួមបញ្ចូលបុគ្គលដែលមានឯកសារបញ្ជាក់ក្នុងបញ្ជីលក្ខខណ្ឌតម្រូវអំពីការផ្តល់ឯកសារបញ្ជាក់ជំនាញថែទាំសុខភាព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ក៏ដូចជាបុគ្គលដែលត្រូវបានអនុញ្ញាតដោយច្បាប់ឱ្យផ្តល់សេវាថែទាំសុខភាពដោយមិនចាំបាច់មានឯកសារបញ្ជាក់។ **បុគ្គលិក និងភ្ញៀវទាំងអស់ បន្ថែមលើអ្នកជំនាញថែទាំសុខភាព ត្រូវបានតម្រូវឱ្យពាក់ម៉ាស់ពេលស្ថិតនៅក្នុងអគារនៃមជ្ឈដ្ឋានថែទាំសុខភាព។**

ខាងក្រោមនេះគឺជាបញ្ជីទូទៅនៃមជ្ឈដ្ឋានថែទាំសុខភាព និងមជ្ឈដ្ឋានថែទាំរយៈពេលវែង៖

- ទីតាំងថែទាំកម្រិតធ្ងន់រួមមានជាអាទិ៍ មន្ទីរពេទ្យនានា។
- ទីតាំងថែទាំកម្រិតធ្ងន់រយៈពេលវែង។
- ទីតាំងស្តារនីតិសម្បទាអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។
- ទីតាំងថែទាំសុខភាពឥរិយាបថអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរួមមានជាអាទិ៍ ទីតាំងវាយតម្លៃនិងព្យាបាល ទីតាំងដែលអាចរស់នៅក្នុងពេលព្យាបាល ទីតាំងបន្សាបជាតិពុលដែលមានសុវត្ថិភាព។
- ទីតាំងដែលអាចរស់នៅក្នុងពេលថែទាំរយៈពេលវែងរួមមានជាអាទិ៍ មណ្ឌលថែទាំជនចាស់ជរា ទីតាំងរស់នៅដែលមានជំនួយ មណ្ឌលថែទាំមនុស្សពេញវ័យជាក្រុម មជ្ឈដ្ឋានផ្តល់ជំនួយនិងសេវារស់នៅជាសហគមន៍ដែលមានលិខិតបញ្ជាក់ និងទីតាំងផ្តល់សេវាធ្វើឱ្យប្រសើរឡើង។
- គ្លីនិកចល័ត ឬយានជំនិះផ្សេងទៀតដែលផ្តល់ការថែទាំសុខភាព។
- ទីតាំងផ្តល់ការព្យាបាលមិនសម្រាកក្នុងមន្ទីរពេទ្យរួមមានជាអាទិ៍ មជ្ឈមណ្ឌលលាងឈាម ការិយាល័យគ្រូពេទ្យ និងទីតាំងថែទាំសុខភាពឥរិយាបថ (រួមមានការិយាល័យគ្រូពេទ្យរោគសតិ អ្នកប្រឹក្សាសុខភាពផ្លូវចិត្ត និងអ្នកជំនាញផ្នែកជំងឺដោយសារការប្រើប្រាស់សារធាតុញៀន)។
- ទីតាំងទន្តពេទ្យ និងឯកទេសផ្នែកទន្តពេទ្យ។
- ទីតាំងចក្ខុសាស្ត្រ និងចក្ខុរោគសាស្ត្រ។
- ឱសថស្ថាន (មិនរួមបញ្ចូលកន្លែងលក់រាយ)។
- ការិយាល័យព្យាបាលដោយម៉ាស្សា (រួមបញ្ចូលកន្លែងដែលបានរៀបចំសម្រាប់ផ្តល់ការម៉ាស្សាក្នុងមជ្ឈដ្ឋានដែលមិនមែនថែទាំសុខភាព ដូចជាមជ្ឈមណ្ឌលហាត់ប្រាណ/សុខុមាលភាព និងស្ប៉ា)។
- ការិយាល័យចាប់សរសៃ។
- មជ្ឈមណ្ឌលសម្រាលកូនដាច់ដោយឡែក និងសេវាពេទ្យឆ្មប។
- ទីតាំងនៅដាច់ដោយឡែក និង/ឬធ្វើចត្តាឡីស័ក។
- ទីតាំងវះកាត់មិនសម្រាកក្នុងមន្ទីរពេទ្យ។
- មជ្ឈមណ្ឌលសង្គ្រោះបន្ទាន់។
- មជ្ឈមណ្ឌលថែទាំក្នុងដំណាក់កាលចុងក្រោយ និង
- មជ្ឈដ្ឋានដែលផ្តល់សេវាថែទាំសុខភាពនៅផ្ទះ ថែទាំនៅផ្ទះ ថែទាំផ្ទាល់ខ្លួន ឬថែទាំក្នុងដំណាក់កាលចុងក្រោយដោយអ្នកផ្តល់សេវាដែលគិតថ្លៃ។

មជ្ឈដ្ឋានថែទាំសុខភាព និងមជ្ឈដ្ឋានថែទាំរយៈពេលវែងមិនរាប់បញ្ចូល៖

- មជ្ឈដ្ឋានដែលព្រឹត្តិការណ៍កីឡា និងទស្សនិកជន ឬព្រឹត្តិការណ៍ប្រមូលផ្តុំមនុស្សផ្សេងទៀតប្រព្រឹត្តទៅ (រួមទាំងនៅពេលដែលគ្រូបង្វឹកអត្តពលកម្មដែលមានឯកសារបញ្ជាក់កំពុងផ្តល់ការថែទាំដល់កីឡាករ) ក្រៅពីកន្លែងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាព ដូចជាកន្លែងដែលរៀបចំសម្រាប់សង្គ្រោះបឋម (ដែលជាមជ្ឈដ្ឋានថែទាំសុខភាព)។
- មណ្ឌលកូនចិញ្ចឹមដែលចេញអាជ្ញាបណ្ណដោយ Department of Children, Youth & Families (DCYF, ក្រសួងកុមារ យុវជន និងគ្រួសារ) ដែលមិនផ្តល់សេវាថែទាំសុខភាពជាចម្បង។
- ទីតាំងស្រាវជ្រាវដែលមិនផ្តល់សេវាថែទាំសុខភាពដល់ប្រជាជន។
- មជ្ឈដ្ឋានថែទាំសុខភាពសត្វ។
- ទីភ្នាក់ងារគ្រប់គ្រងសត្វ។
- អង្គការសង្គមមនុស្សធម៌មិនស្វែងរកប្រាក់ចំណេញ និង
- ហាងលក់កញ្ចាវាយ រួមទាំងហាងដែលអ្នកប្រឹក្សាវេជ្ជសាស្ត្រអំពីកញ្ចាផ្តល់សេវាកម្ម។

ប្រសិនបើទីតាំងថែទាំសុខភាពតម្រូវឱ្យពាក់ម៉ាស់ក្រៅអគារ អ្នកត្រូវតែប្រកាន់ខ្ជាប់តាមវិធាននៃអាជីវកម្មពួកគេ។ សូមមើលព័ត៌មានអំពី "វិធានតាមទីតាំង" ខាងលើ ដើម្បីជ្រាបព័ត៌មានបន្ថែម។ សូមចូលមើលទំព័រអំពីការបង្ការការចម្លងជំងឺ COVID-19 ក្នុងមជ្ឈដ្ឋានថែទាំសុខភាព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ដើម្បីមើលការណែនាំលម្អិត រួមទាំងការណែនាំអំពីការគ្រប់គ្រងប្រភព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងការណែនាំអំពីការទៅជួបគ្រូពេទ្យសម្រាប់ទីតាំងថែទាំសុខភាពមួយចំនួន។

**វិធានតាមទីតាំង**

អាជីវកម្ម អង្គការ គ្រឹះស្ថាន និងទីតាំងនានាមានសិទ្ធិក្នុងការបង្កើតវិធានផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ការពាក់ម៉ាស់នៅក្នុងគ្រឹះស្ថានឬទីតាំងរបស់ពួកគេ។ អាជីវកម្មនានាត្រូវបានតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងអស់ក្នុងលក្ខខណ្ឌតម្រូវរបស់ L&I (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងអាចសម្រេចចិត្តតម្រូវឱ្យពាក់ម៉ាស់ក្នុងមជ្ឈដ្ឋាននានា (ឧ. ក្រៅអាគារ) ដើម្បីឱ្យមានការការពារខ្ពស់ជាងសេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល (ជាភាសាអង់គ្លេសប៉ុណ្ណោះ)

មន្ត្រីសុខាភិបាលសាធារណៈក្នុងមូលដ្ឋានក៏អាចដាក់ចេញនូវសេចក្តីបង្គាប់ឱ្យពាក់ម៉ាស់ការពារបន្ថែម ដើម្បីកាត់បន្ថយការចម្លងជំងឺក្នុងសហគមន៍ផងដែរ។ វិធានទាំងនេះអាចមានការការពារខ្ពស់ជាងសេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ប៉ុន្តែមិនអាចការពារទាបជាងនោះទេ។

បន្ថែមពីនេះ បុគ្គលមួយចំនួនអាចនឹងត្រូវ ឬសម្រេចចិត្តបន្តពាក់ម៉ាស់។ ពួកគេមានសិទ្ធិសម្រេចចិត្តពាក់ម៉ាស់ក្នុងទីសាធារណៈ ទោះបីជានៅពេលដែលសេចក្តីបង្គាប់អំពីការពាក់ម៉ាស់ថ្នាក់មូលដ្ឋានឬរដ្ឋមិនមានសុពលភាពក៏ដោយ។ សូមគោរពតាមការសម្រេចចិត្តពាក់ម៉ាស់របស់ពួកគេដើម្បីការពារខ្លួន គ្រួសារ និងសហគមន៍។ សូមកត់សម្គាល់ថា ប្រសិនបើអ្នកសម្រេចចិត្តពាក់ម៉ាស់ អ្នកអាចនឹងត្រូវបានស្នើឱ្យដោះម៉ាស់ចេញមួយភ្លែតក្នុងស្ថានភាពផ្សេងៗ ដូចជាក្នុងគោលបំណងកំណត់អត្តសញ្ញាណជាដើម។